**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

លេខ : ០៩០ សសរ

# សេចក្ដីសម្រេច

## ស្ដីពី

## ការបង្កើតក្រុមការងារព័ត៌មាន និងបណ្ដាញផ្សព្វផ្សាយសង្គម

### ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ១៨០ អនក្រ.បក ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៤ ស្ដីពីការបង្កើតអគ្គនាយកដ្ឋានលំនៅឋានចំណុះក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ៧៣ អនក្រ.បក ចុះថ្ងៃទី៥ ខែឧសភា ឆ្នាំ២០១៦ ស្ដីពីការបង្កើតអគ្គាធិការដ្ឋានចំណុះក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ២៨៧ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២២ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់មន្ទីរពិសោធន៍ជាតិសំណង់
- យោងតាមការចាំបាច់របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

## សម្រេច

**ប្រការ១.**_

បង្កើតក្រុមការងារព័ត៌មាន និងបណ្ដាញផ្សព្វផ្សាយសង្គម ដែលមានសមាសភាពដូចតទៅ÷

| | | | |
|---|---|---|---|
| ១- | លោកជំទាវ **សេង សុមេត្តា** | រដ្ឋលេខាធិការ | ប្រធាន |
| ២- | លោកជំទាវ **គីម រុនស៊ីណារតន៍** | អនុរដ្ឋលេខាធិការ | អនុប្រធាន |
| ៣- | ឯកឧត្ដម **សេង ថានី** | អនុរដ្ឋលេខាធិការ | សមាជិក |
| ៤- | ឯកឧត្ដម **ហ៊ិន កុសល** | អនុរដ្ឋលេខាធិការ | សមាជិក |
| ៥- | ឯកឧត្ដម **សេង ឡុត** | អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល | សមាជិក |
| ៦- | ឯកឧត្ដម **សួន សុផា** | អគ្គនាយកនៃអគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ | សមាជិក |
| ៧- | ឯកឧត្ដម **ប៉េងហុង សុជាតិខេមរ៉ូ** | អគ្គនាយកនៃអគ្គនាយកដ្ឋានរៀបចំដែនដី និងនគរូបនីយកម្ម | សមាជិក |

| | | | |
|---|---|---|---|
| ៨- | ឯកឧត្តម **ឆាន់ សុវណ្ណផល** | អគ្គនាយកនៃអគ្គនាយកដ្ឋានសំណង់ | សមាជិក |
| ៩- | ឯកឧត្តម **ធ្លាក់ អង្គារ៉ា** | អគ្គនាយកនៃអគ្គនាយកដ្ឋានលំនៅឋាន | សមាជិក |
| ១០- | ឯកឧត្តម **ម៉ែន ចំនួនសុខខេមរា** | អគ្គាធិការនៃអគ្គាធិការដ្ឋាន | សមាជិក |
| ១១- | ឯកឧត្តម **ញ៉ូ ហេង** | អគ្គនាយកនៃមន្ទីរពិសោធន៍ជាតិសំណង់ | សមាជិក |
| ១២- | លោក **សន ប៊ុនមាន** | នាយករងខុទ្ទកាល័យ | សមាជិក |
| ១៣- | លោក **ជាម សុផលមករា** | ប្រធានមជ្ឈមណ្ឌលបណ្ដុះបណ្ដាលវិជ្ជាជីវៈ | សមាជិក |
| ១៤- | លោកស្រី **នូសុវត្ថិ ចាន់វត្តី** | អនុប្រធាននាយកដ្ឋានអភិវឌ្ឍន៍សេដ្ឋកិច្ច កិច្ចការវិនិយោគ និងទំនាក់ទំនងអន្តរជាតិ | សមាជិកាអចិន្ត្រៃយ៍ |

**ប្រការ២._**

ក្រុមការងារព័ត៌មាន និងបណ្ដាញផ្សព្វផ្សាយសង្គម មានភារកិច្ច ÷

- ផ្សព្វផ្សាយសមិទ្ធផលរបស់ក្រសួង រាជរដ្ឋាភិបាល និងកសាងរូបភាពវិជ្ជមាន ដើម្បីលើកកម្ពស់កិត្យានុភាពរបស់ព្រះរាជាណាចក្រកម្ពុជាទាំងក្នុងប្រទេស និងលើឆាកអន្តរជាតិ
- ផ្សព្វផ្សាយអំពីគោលនយោបាយ ច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងសមិទ្ធផលរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ តាមប្រព័ន្ធបណ្ដាញសង្គមនានា ដើម្បីឱ្យបានជ្រួតជ្រាបដល់គ្រប់ស្រទាប់មហាជន និងប្រជាជន
- ផ្សព្វផ្សាយព័ត៌មានអំពីសកម្មភាពរបស់ថ្នាក់ដឹកនាំ និងមន្ត្រីរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ចងក្រងនូវរាល់ព័ត៌មានដែលពាក់ព័ន្ធនឹងកិច្ចការរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ផ្សព្វផ្សាយសេចក្ដីប្រកាសព័ត៌មាន សេចក្ដីថ្លែងការណ៍ និងសេចក្ដីបំភ្លឺឆ្លើយតបនឹងព័ត៌មានក្លែងក្លាយឱ្យបានទាន់ពេលវេលា និងមានប្រសិទ្ធភាពខ្ពស់
- ទំនាក់ទំនងជាមួយក្រសួង ស្ថាប័ន និងអង្គភាពនានា ដើម្បីប្រមូលព័ត៌មានពាក់ព័ន្ធនឹងកិច្ចការដែលជាសមត្ថកិច្ចរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ផ្ដួចផ្ដើម និងដឹកនាំក្រុមលេខា ដកស្រង់ ចងក្រង និងផលិតឯកសារជារូបភាព ឬវីឌីអូខ្លីៗ ឬជាសារសំឡេង ដើម្បីផ្សព្វផ្សាយពីគោលនយោបាយ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងវិស័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ព្រមទាំងសមិទ្ធផលសំខាន់ៗរបស់ក្រសួង តាមប្រព័ន្ធបណ្ដាញសង្គម ដូចជា÷ Website, Facebook, Telegram, TikTok, YouTube...
- តាមដានព័ត៌មាន Facebook, Telegram របស់សម្ដេចតេជោ សម្ដេចធិបតីនាយករដ្ឋមន្ត្រី ដើម្បីរាយការណ៍ និងឆ្លើយតបទៅនឹងមតិផ្សេងៗ ក្នុង Facebook
- តាមដានព័ត៌មានពាក់ព័ន្ធនឹងស្ថាប័នព្រឹទ្ធសភា រដ្ឋសភា ក្រសួងមហាផ្ទៃ និងសហភាពសហព័ន្ធយុវជនកម្ពុជា
- បំពេញភារកិច្ចផ្សេងៗទៀតដែលប្រធានស្ថាប័នប្រគល់ជូន។

**ប្រការ៣._**

សមាជិក សមាជិកានៃក្រុមការងារព័ត៌មាន និងបណ្ដាញផ្សព្វផ្សាយសង្គម ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន។ ក្នុងករណីប្រធានអវត្តមាន អនុប្រធាន ត្រូវដឹកនាំការប្រជុំតាមការប្រគល់សិទ្ធិរបស់ប្រធាន។

**ប្រការ៤._**

ក្រុមការងារព័ត៌មាន និងបណ្ដាញផ្សព្វផ្សាយសង្គម មានក្រុមលេខាជាជំនួយការ ដែលមានសមាសភាព និងតួនាទី ដូចខាងក្រោម÷

ក-សមាសភាព

| | | |
|---|---|---|
| ១- លោកស្រី **នូសុវត្ថិ ចាន់វត្តី** | អនុប្រធាននាយកដ្ឋានអភិវឌ្ឍន៍សេដ្ឋកិច្ច កិច្ចការវិនិយោគ និងទំនាក់ទំនងអន្តរជាតិ | ប្រធាន |
| ២- លោក **ស៊ីវ វិសេស** | ជំនួយការឯកឧត្តមរដ្ឋលេខាធិការប្រចាំការ | អនុប្រធាន |
| ៣- លោកស្រី **ច័ន្ទ សុរិយា** | អនុប្រធាននាយកដ្ឋានកិច្ចការវិវាទដីធ្លី | អនុប្រធាន |
| ៤- លោក **ឫទ្ធី រតនៈជ័យសិទ្ធិ** | អនុប្រធាននាយកដ្ឋានសម្បទានដីសង្គមកិច្ច | អនុប្រធាន |
| ៥- លោក **សំរិទ្ធ សុចិត្រា** | អនុប្រធាននាយកដ្ឋាននីតិកម្ម | អនុប្រធាន |
| ៦- លោក **ជិន វណ្ណចំន្ទ** | អនុប្រធាននាយកដ្ឋានរដ្ឋបាល និងកិច្ចការទូទៅ | សមាជិក |
| ៧- លោក **ហ៊ីម វិជិត** | អនុប្រធាននាយកដ្ឋានបច្ចេកវិទ្យាព័ត៌មានសុរិយោដី | សមាជិក |
| ៨- លោក **ឡាយ ចំន្ទធា** | អនុប្រធាននាយកដ្ឋាននីតិកម្ម | សមាជិក |
| ៩- លោក **អើ សំបុល** | អនុប្រធាននាយកដ្ឋានមូលនិធិនិងឥណទានលំនៅឋាន | សមាជិក |
| ១០- លោក **សុខ ម៉ារ៉ា** | អនុប្រធាននាយកដ្ឋានអធិការកិច្ចភូមិបាល | សមាជិក |
| ១១- លោក **ផូង លីជីហ៊ុន** | អនុប្រធាននាយកដ្ឋានបទប្បញ្ញត្តិ ផែនការ និង ទំនាក់ទំនងសហប្រតិបត្តិការការងារលំនៅឋាន | សមាជិក |
| ១២- កញ្ញា **សុខ មុី** | អនុប្រធាននាយកដ្ឋានស្រាវជ្រាវបច្ចេកទេសសំណង់ | សមាជិកា |
| ១៣- លោកស្រី **ស្រ៊ុន ចំន្ទរស្មី** | អនុប្រធានមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិកា |
| ១៤- កញ្ញា **ចាន់ គុជមុន្នីមុំ** | ជំនួយការក្រសួង | សមាជិកា |
| ១៥- លោក **នាង សុខជា** | ប្រធានការិយាល័យកិច្ចការវិវាទដីធ្លី | សមាជិក |
| ១៦- លោក **ពិន សុវណ្ណារិទ្ធ** | ប្រធានការិយាល័យស្រាវជ្រាវទីផ្សារ សេវាកម្មហិរញ្ញវត្ថុ | សមាជិក |
| ១៧- លោក **ថោង សុបញ្ញាភា** | ប្រធានការិយាល័យកិច្ចការទូទៅ ព័ត៌មានវិទ្យា និងឯកសារ | សមាជិក |
| ១៨- លោក **រាម កេរ្តិ៍សុវណ្ណា** | ប្រធានការិយាល័យបទប្បញ្ញត្តិ | សមាជិក |
| ១៩- លោក **សូរ ណារ៉ៃឡុន** | ប្រធានការិយាល័យតម្កល់ឯកសារ | សមាជិក |
| ២០- លោក **ប្រាក់ វិចិត្រ** | អនុប្រធានការិយាល័យកិច្ចការវិវាទដីធ្លី | សមាជិក |
| ២១- លោក **ស៊ឹម សែនស្រស់** | អនុប្រធានការិយាល័យគាំទ្របច្ចេកទេស សម្បទានដីសង្គមកិច្ច | សមាជិក |
| ២២- លោក **អន ម៉ិនថន** | អនុប្រធានការិយាល័យអភិវឌ្ឍន៍សេដ្ឋកិច្ចនិងស្ថិតិ | សមាជិក |
| ២៣- លោក **ផង់ ពន្លក** | អនុប្រធានការិយាល័យត្រួតពិនិត្យបច្ចេកទេស | សមាជិក |
| ២៤- លោកស្រី **ជា ស្រីនិត** | មន្ត្រី | សមាជិកា |
| ២៥- លោក **ទាវ សារៈមុនិន្ទ** | មន្ត្រី | សមាជិក |
| ២៦- លោក **សំអឿន សុធីរ៉ូ** | មន្ត្រីនៃនាយកដ្ឋានបច្ចេកទេសនិងអភិវឌ្ឍន៍លំនៅឋាន | សមាជិក |
| ២៧- កញ្ញា **រស់ ចាន់ត្រា** | មន្ត្រីនៃនាយកដ្ឋាននីតិកម្ម | សមាជិកា |
| ២៨- លោក **អ៊ាង និតិតព ដេនីស** | មន្ត្រីកម្មសិក្សាការី | សមាជិក |
| ២៩- លោកស្រី **អ៊ាង និធិជូនី ដីណេ** | មន្ត្រីកម្មសិក្សាការី | សមាជិកា |
| ៣០- លោក **វ៉េន ប្រិម្យប្រិយ** | មន្ត្រីកម្មសិក្សាការី | សមាជិក |
| ៣១- កញ្ញា **ជាតិ ចំន្ទបុណ្ណមី** | មន្ត្រីកម្មសិក្សាការី | សមាជិកា |
| ៣២- លោក **ចេង ណារ៉ាក់** | មន្ត្រីជាប់កិច្ចសន្យា | សមាជិក |
| ៣៣- លោក **ស៊ីវ សុធារ័ត្ន** | មន្ត្រីជាប់កិច្ចសន្យា | សមាជិក |
| ៣៤- លោក **ម៉ម ភក្តី** | មន្ត្រីជាប់កិច្ចសន្យា | សមាជិក |

៣៥- កញ្ញា **ខិន មុិសស៊ើល** មន្ត្រីហាត់ការ សមាជិកា
៣៦- លោក **នុត ថាវី** មន្ត្រីស្ម័គ្រចិត្ត សមាជិក
៣៧- លោក **នុត រ៉ាវីន** មន្ត្រីស្ម័គ្រចិត្ត សមាជិក។

**ខ-ភារកិច្ច**

- រៀបចំបង្កើតមាតិកាព័ត៌មាន និងខ្លឹមសារនៃកិច្ចប្រជុំ និងសកម្មភាពនានារបស់ថ្នាក់ដឹកនាំ និងមន្ត្រី ដើម្បីផ្សព្វផ្សាយ
- ប្រមូលនិងចងក្រងសកម្មភាពរបស់ថ្នាក់ដឹកនាំ និងមន្ត្រីរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដើម្បីផ្សព្វផ្សាយតាមបណ្តាញសង្គមរបស់ក្រសួង
- ផលិតឯកសារជាសារសំឡេង រូបភាព ឬវីឌីអូខ្លីៗ ដើម្បីផ្សព្វផ្សាយតាមប្រព័ន្ធបណ្តាញផ្សព្វផ្សាយសង្គម ជាអាទិ៍ Website, Facebook, Telegram, TikTok, YouTube ដែលពាក់ព័ន្ធនឹងគោលនយោបាយ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត ក្នុងវិស័យដីធ្លី សំណង់ និងលំនៅឋាន
- វាយការណ៍ព័ត៌មាន Facebook, Telegram របស់សម្តេចតេជោ និងសម្តេចធិបតីនាយករដ្ឋមន្ត្រី ពាក់ព័ន្ធនឹងកិច្ចការរបស់ក្រសួង
- វាយការណ៍ព័ត៌មានពាក់ព័ន្ធនឹងស្ថាប័នព្រឹទ្ធសភា រដ្ឋសភា ក្រសួងមហាផ្ទៃ និងសហភាពសហព័ន្ធយុវជនកម្ពុជា
- តាមដានសំណើ និងសំណូមពររបស់មហាជនតាមប្រព័ន្ធបណ្តាញសង្គមពាក់ព័ន្ធនឹងកិច្ចការជំនាញរបស់ក្រសួង ដើម្បីរៀបចំការបំភ្លឺឆ្លើយតប
- បំពេញភារកិច្ចផ្សេងៗទៀតដែលប្រធានក្រុមការងារព័ត៌មាន និងបណ្តាញផ្សព្វផ្សាយសង្គមប្រគល់ជូន។

**ប្រការ៥._**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៦._**

នាយកខុទ្ទកាល័យ គ្រប់អគ្គនាយក អគ្គាធិការ គ្រប់ប្រធាននាយកដ្ឋាន អង្គភាពពាក់ព័ន្ធ និងសាមីខ្លួនដូចមានរាយនាមក្នុងប្រការ១ និងប្រការ៤ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ សុក្រ ៦កើត ខែ អស្សុជ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ តុលា ឆ្នាំ២០២៣

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

**សាយ សំអាល់**

**កន្លែងទទួល ÷**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងមុខងារសាធារណៈ
- ក្រសួងព័ត៌មាន
- ដូចប្រការ ៦
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ